Ottawa County Health Department

# សន្លឹកព័ត៌មានសាធារណៈ

## រោគថ្លើមប្រភេទ A [HEPATITIS A]

**តើរោគថ្លើមប្រភេទ A គឺជាអ្វី?**

រោគថ្លើមប្រភេទ A គឺជាជម្ងឺមួយ បង្កដោយវីរុស ដែលប៉ះពាល់ដល់ថ្លើម ។

**តើរោគថ្លើមប្រភេទ A ត្រូវបានឆ្លងតាមរបៀបអ្វីខ្លះ?**

រោគថ្លើមប្រភេទ A មាននៅក្នុងលាមក (អាចម៏) របស់អ្នកដែលមានរោគថ្លើមប្រភេទ A ។ វាត្រូវបានឆ្លងតាមរយៈរបៀបទាំងឡាយខាងក្រោមនេះ ។

- ដាក់របស់មួយក្នុងមាត់ ដែលធ្លាប់ប៉ះនឹងលាមករបស់អ្នកមានរោគថ្លើមប្រភេទ A
- តាមរយៈទឹក ឬអាហារមិនស្អាត
- តាមរយៈការរួមរ័កតាមផ្លូវទ្វារធំ

**តើមានរោគសញ្ញាអ្វីខ្លះ?**

រោគសញ្ញាអាចមានរួមទាំងៈ

- រងា
- ក្តៅខ្លួន
- ចុកចាប់សាច់ដុំ
- នឿយហត់យ៉ាងខ្លាំង
- មិនចង់បរិភោគ
- អារម្មណ៏ចង់ក្អួត
- ឈឺក្រពះ
- ភ្នែក ឬស្បែកពណ៌លឿង
- អ្នកខ្លះមិនមានរោគសញ្ញាសោះ

រោគសញ្ញាចាប់ផ្តើម 15-20 ថ្ងៃក្រោយពីការឆ្លងមេរោគ ។ ជម្ងឺនេះអាចមានរយៈពេលខ្លី គឺ 1-2 អាទិត្យ ឬ ក្នុងករណីដ៏ធ្ងន់អាចមានរាប់ខែក៏ថាបានដែរ ។

**តើរោគថ្លើមប្រភេទ A ត្រូវបានវិនិច្ឆ័យរោគយ៉ាងដូចម្តេច?**

ដោយការពិនិត្យឈាមមួយ សម្រាប់រោគថ្លើមប្រភេទ A ។

**តើរោគថ្លើមប្រភេទA ត្រូវបានព្យាបាលយ៉ាងដូចម្តេច?**

គ្មានវិធីព្យាបាលរោគថ្លើមឱ្យជាទេ ។ ការសម្រាក គឺសំខាន់ណាស់ ។ អ្នកដែលមានរោគថ្លើមប្រភេទ A ត្រូវចៀសវាងស្រា និងគ្រឿងណាផ្សេងទៀត ដែលអាចធ្វើឱ្យអន្តរាយដល់ថ្លើម ។

**តើរោគថ្លើមប្រភេទ A អាចបង្ការបានយ៉ាងដូចម្តេច?**

- ថ្នាំអ៊ិមយូន ក្លូប៊្យូលិន ត្រូវចាក់ឱ្យអ្នកក្នុងផ្ទះ និងដៃគូររួមដំណេកទាំងអស់ របស់អ្នកកើតជម្ងឺនេះ ដើម្បីជួយបង្ការ ឬបន្ធូរជម្ងឺ ។ វាត្រូវចាក់នៅក្នុងរយៈពេល 2 អាទិត្យក្រោយពីឆ្លងមេរោគ ។
- ការលាងដៃយ៉ាងប្រុងប្រយ័ត្នជាការសំខាន់ណាស់ ជាពិសេសក្រោយពីបត់ជើង ឬដូរកន្ទបក្មេង ឬមុនបរិភោគអាហារ ។
- កន្សែង និងរបស់របរមុជទឹកផ្សេងៗរបស់អ្នកមានរោគថ្លើមប្រភេទA គួរតែរក្សាឱ្យផុតពីសមាជិកគ្រួសារឯទៀតៗ ។
- លាង និងសម្លាប់មេរោគបង្គន់រៀងរាល់ថ្ងៃ ។

រោគថ្លើមប្រភេទ A អាចបង្ការបាន ដោយចាក់ថ្នាំបង្ការរោគថ្លើមប្រភេទA ។ ថ្នាំបង្ការនេះ គួរតែចាក់ឱ្យអ្នកធ្វើដំណើរទៅប្រទេសដែលមានរោគថ្លើមប្រភេទ A ច្រើន អ្នកដែលមានរោគថ្លើម Bឬ C អ្នកចាក់ថ្នាំញៀន ហើយនិងអ្នកដែលនិយមរួមរ័កតាមផ្លូវទ្វារធំ ។ វាក៏ត្រូវបានអនុសាសសម្រាប់កុមារដែលឋិតក្នុងអាយុមួយចំនួន ។

**សម្រាប់ព័ត៌មានបន្ថែមអំពីរោគថ្លើមៈ**

Ottawa County Health Department
www.miOttawa.org
Medline Plus/National Institutes of Health
www.nlm.nih.gov/medlineplus/ency/article/000278.htm

12251 James St., Suite 400
Holland, MI 49424
ទូរស័ព្ទ: (616) 396-5266
ទូរសារ: (616) 393-5643
វិបសាយ: www.miOttawa.org